ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សូមក្រាបបង្គំទូលថ្វាយ

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

***ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសដ៏នក្ខត្តឫក្ស ពោរពេញដោយក្ដីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ទូលព្រះបង្គំនិងភរិយា សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត ក្រាបបង្គំទូលថ្វាយ នូវព្រះរាជសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់កូនចៅប្រជារាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា។

នាឱកាសដ៏ថ្លៃថ្លាមហាប្រសើរនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតអភិវន្ទក្រាបបង្គំសម្ដែងថ្វាយនូវអំណរសាទរ និងកតញ្ញូកតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុត ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះរាជគុណូបការៈ និងមហាករុណាទិគុណដ៏ថ្លៃថ្លាឧត្តុង្គឧត្តម ប្រកបដោយព្រះព្រហ្មវិហារធម៌ និងក្ដីមេត្តាធម៌ដល់កូនចៅប្រជារាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្នុងព្រះបរមសិរីរាជសម្បត្តិដ៏ពិសិដ្ឋ ទ្រង់តែងបំពេញព្រះរាជបូជនីយកិច្ចដ៏ខ្ជាប់ខ្ជួន យកព្រះរាជហឫទ័យទុកដាក់ជាទីបំផុតដល់សុខទុក្ខរបស់ប្រជារាស្ត្រទូទៅ ដើម្បីភាពសុខដុមរមនា និងសេចក្ដីសុខក្សេមក្សាន្តរបស់កូនចៅប្រជារាស្ត្រទូទៅ។

ជាថ្មីម្ដងទៀត ក្នុងឱកាសដ៏មហាជ័យមង្គលនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តលើកហត្ថប្រណម្យបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងព្រះរាជតេជបារមី នៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ សូមប្រោសព្រះរាជទានប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ប្រកបដោយព្រះបរមសុខ មានព្រះរាជសុខភាពល្អបរិបូរ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ។

សូម **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្ដីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃអង្គារ ៤ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៤ email: generalsec@mod.gov.kh